**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
១១១ ៕ ១១១

**ក្រសួងអប់រំ យុវជន និង កីឡា**
**លេខ: ៧៥៧៩ អយក.ប្រក**

លិខិតចូល
ថ្ងៃទី ៣០ ខែ មករា ឆ្នាំ 2007

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅ នៃ ការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញព្រះរាជក្រឹត្យលេខនស.រកត.០៧០៤-១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រមលេខ នសរ-កម ០១៩៦-០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ ខែ មីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៧៩៦.៥២ ចុះថ្ងៃទី២៦ កក្កដា ១៩៩៦ ស្តីអំពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ។
- បានឃើញលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ១៨៥២ សជណ.អវ.ចុះថ្ងៃទី២៣ ធ្នូ ១៩៩៩ ស្តីពីការលុបប្រឡងសញ្ញាប័ត្រមធ្យមសិក្សាលើកទី២។
- យោងតាមការចាំបាច់របស់ ក្រសួងអប់រំ យុវជន និងកីឡា។

## សម្រេច

**ប្រការ ១-** មណ្ឌលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា រៀងរាល់ឆ្នាំសិក្សា។

**ប្រការ ២-** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង និងនាយកគ្រឹះស្ថានសិក្សាដែលគ្រឹះស្ថានត្រូវបានកំណត់ជាមណ្ឌលប្រឡង មានភារៈរៀបចំបន្ទប់ប្រឡង កម្រងសលាកប័ត្រឯកត្តជនរបស់បេក្ខជន បញ្ជីផ្សេងៗ និងសំភារៈចាំបាច់សម្រាប់ការប្រព្រឹត្តទៅនៃការប្រឡង ឱ្យហើយស្រេចមុនបើកសម័យប្រឡង។

**ប្រការ ៣-** មណ្ឌលប្រឡងនីមួយៗ ត្រូវមានប្រធាន អនុប្រធាន និងសមាជិកមេប្រយោគមួយចំនួនតាមការចាំបាច់នៃមណ្ឌលប្រឡង។

**ប្រការ ៤-** សមាសភាព និងចំនួនព្រមទាំងលិខិតឧទ្ទេសនាមមេប្រយោគ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួង

អប់រំ យុវជន និងកីឡា តាមសំណើរបស់ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ។

**ប្រការ ៥** - បន្ទប់ប្រឡងនីមួយៗ ត្រូវដាក់បេក្ខជនត្រឹម២៥ «ម្ភៃប្រាំ» នាក់។ បើមានបេក្ខជននៅសល់ ០៥ «ប្រាំ» នាក់ឡើងទៅ ត្រូវដាក់ក្នុងបន្ទប់មួយដោយឡែក។

**ប្រការ ៦** - ប្រធានមណ្ឌលនៃមណ្ឌលសំណេរនីមួយៗ ជាអ្នកទទួលខុសត្រូវរួម ក្នុងការដំណើរការប្រព្រឹត្តទៅនៃការប្រឡងទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេសចំពោះក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ ៧** - ប្រធានមណ្ឌល ត្រូវសហការ ឬធ្វើអន្តរាគមន៍ដល់អាជ្ញាធរមានសមត្ថកិច្ចនានាក្នុងខេត្ត-ក្រុងនៃមណ្ឌលប្រឡងក្នុងករណីចាំបាច់ ដើម្បីរក្សារបៀបរៀបរយក្នុងពេលប្រឡង។

**ប្រការ ៨** - មណ្ឌល ឬអនុមណ្ឌលប្រឡងណាមួយដែលមិនមានភាពប្រក្រតីតាមលក្ខការណ៍ នៃការប្រឡង ប្រធានមណ្ឌលនៃមណ្ឌល ឬអនុមណ្ឌលនោះត្រូវរាយការណ៍ជាបន្ទាន់មក គណៈមេប្រយោគទូទាំងខេត្ត និងអាជ្ញាធរដែនដីដើម្បីដោះស្រាយ ឬសុំការសំរេចពីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ ៩** - ប្រធានមណ្ឌល ត្រូវបែងចែកភារកិច្ចដល់អនុប្រធាន និងសមាជិកមេប្រយោគអោយទទួលខុសត្រូវតាមមុខងាររៀងៗខ្លួន។

**ប្រការ ១០**-ភារកិច្ចគណៈកម្មការ អនុគណៈកម្មការ និងសមាជិកមេប្រយោគនឹងមានចែងក្នុងសេចក្តីណែនាំមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ ១១**- នឹងអនុញ្ញាតឱ្យចុះឈ្មោះប្រឡងបាន សិស្សថ្នាក់ទី៩ នៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជន ដែលបានរៀននៅមធ្យមសិក្សាបឋមភូមិគ្រប់កំរិតថ្នាក់ និងរៀនចប់ កម្មវិធីសិក្សាថ្នាក់ទី៩ដោយគោរពបានត្រឹមត្រូវនូវបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមធ្យមសិក្សា ហើយត្រូវបានវាយតំលៃផ្នែកសីលធម៌រស់នៅប្រចាំឆ្នាំចាប់ពីមធ្យមឡើងទៅ។ ពាក្យសុំចុះឈ្មោះ ប្រឡងមានបិទតែម ត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាតាមឋានានុក្រម។

**ប្រការ ១២**-អាចសុំចុះឈ្មោះប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ជាបេក្ខជនស្វ័យរិនបាន អតីតបេក្ខជនដែលបានប្រឡងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ។

**ប្រការ ១៣**- បេក្ខជន ត្រូវភ្ជាប់នឹងពាក្យសុំប្រឡងរបស់ខ្លួននូវ ÷

- សលាកប័ត្រឯកត្តជនទំហំ១៥ស.ម គុណនឹង ២១ស.ម មានបិទរូបថតថ្មីថតចំពីមុខទំហំ៤ស.ម គុណនឹង ៦ស.ម ចំនួន ៤សន្លឹក។
- បង្កាន់ដៃបង់សិទ្ធិប្រឡង ១ច្បាប់។
- រូបថត ថតថ្មី ថតចំពីមុខ ទំហំ៤ស.ម គុណនឹង ៦ស.ម «រូបថតដែលបានបិទលើសលាកប័ត្រឯកត្តជន» ចំនួន ៣សន្លឹក។
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ១សន្លឹក។
- សៀវភៅសិក្សាគារិក «ចំពោះសិស្សសាលាឯកជន»។

**ប្រការ ១៤**-ពាក្យសុំចុះឈ្មោះប្រឡង នឹងត្រូវប្រមូលផ្តុំតាមគ្រឹះស្ថានសិក្សាដែលខ្លួនសិក្សា។ នាយកគ្រឹះស្ថានសិក្សាត្រូវប្រមូលសំណុំលិខិតរបស់បេក្ខជន បញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដើម្បីធ្វើការបែងចែកនាមត្រកូលបេក្ខជនតាមលំដាប់អក្ខរក្រម (លំដាប់ ព្យញ្ជនៈ និង ស្រៈ) ទៅតាមបន្ទប់ប្រឡង។

**ប្រការ ១៥**-បេក្ខជនស្វ័យរិន ត្រូវដាក់ពាក្យសុំប្រឡង ដោយមានបញ្ជាក់សម័យប្រឡង មណ្ឌលប្រឡង

លេខបន្ទប់ លេខតុ នៃសម័យប្រឡងមុន នៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងដែលសាមីខ្លួនបានសុំប្រឡងពីមុន។ បើមានបំណងចង់ប្រឡងនៅខេត្ត-ក្រុងថ្មីដែលខ្លួនបានប្តូរលំនៅដ្ឋាននោះត្រូវ មានសេចក្តីបញ្ជាក់លើពាក្យសុំប្រឡងពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងដែលសាមីខ្លួនបានប្រឡងធ្លាក់ពីមុន។

**ប្រការ ១៦**-មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងត្រូវធ្វើបញ្ជីរាយនាមបេក្ខជនផ្ញើទៅក្រសួងអប់រំ យុវជន និងកីឡា «នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ» ដើម្បីពិនិត្យ និងសម្រេចលើបេក្ខភាព។

**ប្រការ ១៧**-បេក្ខជនត្រូវអនុវត្តតាមបទបញ្ញត្តិទូទៅនៃការប្រឡង ដែលមានចែងក្នុងអត្ថបទមួយដោយឡែក។

**ប្រការ ១៨**- វិញ្ញាសា ថេរវេលា និងពិន្ទុនៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ នឹងត្រូវបានកំណត់ដូចតទៅ ៖

| | | | |
|---|---|---|---|
| ១- ភាសាខ្មែរ | រយៈពេល | ២ម៉ោង | ត្រូវបានពិន្ទុពី ០ ដល់ ១០០ |
| ២- គណិតវិទ្យា | រយៈពេល | ២ម៉ោង | ត្រូវបានពិន្ទុពី ០ ដល់ ១០០ |
| ៣- រូបវិទ្យា | រយៈពេល | ៤០នាទី | ត្រូវបានពិន្ទុពី ០ ដល់ ៣០ |
| ៤- គីមី | រយៈពេល | ៤០នាទី | ត្រូវបានពិន្ទុពី ០ ដល់ ២៨ |
| ៥- ជីវវិទ្យា | រយៈពេល | ៤០នាទី | ត្រូវបានពិន្ទុពី ០ ដល់ ២៨ |
| ៦- ផែនដីវិទ្យា | រយៈពេល | ៤០នាទី | ត្រូវបានពិន្ទុពី ០ ដល់ ២៨ |
| ៧- ប្រវត្តិវិទ្យា | រយៈពេល | ៤០នាទី | ត្រូវបានពិន្ទុពី ០ ដល់ ២៨ |
| ៨- ភូមិវិទ្យា | រយៈពេល | ៤០នាទី | ត្រូវបានពិន្ទុពី ០ ដល់ ២៨ |
| ៩- សីលធម៌-ពលរដ្ឋវិជ្ជា | រយៈពេល | ៤០នាទី | ត្រូវបានពិន្ទុពី ០ ដល់ ៣០ |
| ១០- ភាសាបរទេស | រយៈពេល | ៤៥នាទី | ត្រូវបានពិន្ទុពី ០ ដល់ ៥០ |

វិញ្ញាសានីមួយៗនឹងត្រូវបានពិន្ទុសូន្យចំពោះបេក្ខជនអវត្តមាន ឬបេក្ខជនដែលមិនបានប្រគល់សន្លឹកកិច្ចការដល់គណៈមេប្រយោគ លើកលែងតែវិញ្ញាសាភាសាបរទេសដែលជាវិញ្ញាសាតាមស្ម័គ្រ។

**ប្រការ ១៩**- បេក្ខជនទាំងឡាយ អាចជ្រើសរើសយកភាសាតែមួយប៉ុណ្ណោះ ក្នុងចំណោមភាសាបារាំង ឬភាសាអង់គ្លេស នៅពេលធ្វើវិញ្ញាសាភាសាបរទេស។

**ប្រការ ២០**- ពិន្ទុភាសាបរទេសនឹងគិតយកតែពិន្ទុដែលបេក្ខជនធ្វើបានលើសពី២៥ ទៅបូកបញ្ចូលជាមួយពិន្ទុមុខវិជ្ជាផ្សេងៗទៀត។

**ប្រការ ២១**- ប្រធានវិញ្ញាសាប្រឡង ត្រូវយកតាមកម្មវិធីសិក្សាថ្នាក់ទី៩ នៃមធ្យមសិក្សាបឋមភូមិ។ វិញ្ញាសាទាំងឡាយជាវិញ្ញាសាសរសេរទាំងអស់។

**ប្រការ ២២**-ចំពោះសិស្សពិការភ្នែក អនុរក្ស ត្រូវអានប្រធានវិញ្ញាសា ឱ្យបេក្ខជនស្តាប់ ឬកត់ត្រា ដើម្បីធ្វើចម្លើយ ហើយត្រូវទូទាត់រយៈពេលហៅប្រធានវិញ្ញាសា តែមិនឱ្យប៉ះពាល់ដល់ការប្រព្រឹត្តទៅ នៃវិញ្ញាសាបន្ទាប់។ គណៈមេប្រយោគទូទាំងខេត្ត-ក្រុងប្រចាំមណ្ឌលសំណេរ ត្រូវសំរេចដកសំណួរណា ដែលពាក់ព័ន្ធនឹងគំនូរ។

**ប្រការ ២៣**- ប្រធានវិញ្ញាសាទាំងឡាយត្រូវជ្រើសរើស ឬ តាក់តែងដោយក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ ២៤**- ប្រធានវិញ្ញាសាទាំងឡាយ ដែលបានជ្រើសរើសរួចហើយ ត្រូវដាក់ក្នុងស្រោមសម្ងាត់បិទជិត និងប្រថាប់ត្រា ហើយត្រូវបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចដែលមានមណ្ឌលប្រឡង តាមរយៈ

មេប្រយោគទូទាំងខេត្ត ឱ្យថែរក្សាទុក ៣៦ម៉ោងមុនពេលប្រកាសចាប់ផ្តើមប្រឡង។

**ប្រការ ២៥-** អាជ្ញាធរមានសមត្ថកិច្ច ដែលថែរក្សាវិញ្ញាសាទាំងនោះ ត្រូវប្រគល់ឱ្យគណៈមេប្រយោគទូទាំងខេត្ត នៅថ្ងៃចាប់ផ្តើមការប្រឡងមួយម៉ោង មុនពេលបើកសម័យប្រឡង។

**ប្រការ ២៦-** ការប្រគល់ឱ្យ និងការទទួលយកវិញ នូវប្រធានវិញ្ញាសាប្រឡងត្រូវមានការទទួលខុសត្រូវទាំងសងខាង ដោយមានកំណត់ហេតុជាផ្លូវការផង។

**ប្រការ ២៧-** វិញ្ញាសានីមួយៗ ត្រូវមានចំនួនសន្លឹកវិញ្ញាសា ស្មើនឹងចំនួនបេក្ខជន។ បើខ្វះត្រូវចម្លងបន្ថែមបង្គ្រប់ភ្លាម។

**ប្រការ ២៨-** ដំណើរការកំណែត្រូវប្រព្រឹត្តទៅនៅមណ្ឌលកំណែប្រមូលផ្តុំនៅទីរួមខេត្ត-ក្រុង។

**ប្រការ ២៩-** កិច្ចការបេក្ខជនពិការភ្នែក ត្រូវធ្វើកំណែពិសេស ទៅតាមអត្រាកំណែដោយខ្សែក ដោយគ្រូបង្រៀនសិស្សពិការភ្នែក។

**ប្រការ ៣០-** មណ្ឌលកំណែត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការមណ្ឌលកំណែដឹកនាំដោយប្រធានមួយនាក់។ ប្រធានមណ្ឌលកំណែជាប្រធាន ឬអនុប្រធានមេប្រយោគទូទាំងខេត្ត-ក្រុង។

**ប្រការ ៣១-** បន្ទាប់ពីបញ្ចប់ដំណើរការវិញ្ញាសាសរសេរ តំណាងមេប្រយោគទូទាំងខេត្ត-ក្រុង នីមួយៗ និងប្រធានមណ្ឌលនៃមណ្ឌលសំណេរនីមួយៗ ត្រូវប្រមូលកិច្ចការបេក្ខជន មកប្រគល់អោយប្រធានមណ្ឌលកំណែ។

**ប្រការ ៣២-** ប្រធាន-អនុប្រធានមណ្ឌលសំណេរនីមួយៗ ត្រូវចូលរួមបន្តការងារនៅមណ្ឌលកំណែ និងអនុវត្តភារកិច្ចតាមការចាត់តាំងរបស់ប្រធានមណ្ឌលកំណែ។

**ប្រការ ៣៣-** ពេលចប់ដំណើរការកំណែប្រធានមណ្ឌលសំណេរត្រូវចុះហត្ថលេខាលើតារាងស្រង់ពិន្ទុ បញ្ជីរបស់មណ្ឌលខ្លួន និងប្រគល់ឯកសារទាំងឡាយពាក់ព័ន្ធនឹងការងារប្រឡងជូនប្រធានមណ្ឌលកំណែ។

**ប្រការ ៣៤-** កិច្ចការបេក្ខជននីមួយៗ ត្រូវកែដោយសមាជិកកំណែពីរនាក់ជាដាច់ខាត តាមតារាងអត្រាកំណែដែលគណៈមេប្រយោគបានសម្រេច។

**ប្រការ ៣៥-** ពិន្ទុសរុបនៃពិន្ទុគ្រប់វិញ្ញាសាហៅថាពិន្ទុប្រឡងថ្នាក់ជាតិ ជាពិន្ទុលើ៤០០ ។

**ប្រការ ៣៦-** ពិន្ទុប្រចាំឆ្នាំស្មើនឹងមធ្យមភាគពិន្ទុឆមាសទី១បូកនឹងមធ្យមភាគពិន្ទុឆមាសទី២ជាពិន្ទុលើ ១០០។

**ប្រការ ៣៧-** ពិន្ទុប្រឡងស្មើនឹងពិន្ទុប្រចាំឆ្នាំ បូកនឹងពិន្ទុប្រឡងថ្នាក់ជាតិ។

**ប្រការ ៣៨-** នឹងត្រូវប្រកាសថាប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិបេក្ខជនទាំងឡាយណាដែលបានពិន្ទុប្រឡងចាប់ពី២៥០ឡើងទៅ និងបេក្ខជនស្វ័យរិនទាំងឡាយណាដែលបានពិន្ទុប្រឡងថ្នាក់ជាតិចាប់ពី២០០ឡើងទៅ ដោយឥតមានពិន្ទុសូន្យចំពោះវិញ្ញាសាណាមួយ លើកលែងតែវិញ្ញាសាភាសាបរទេស។

ក្នុងករណីចាំបាច់ណាស់ គណៈមេប្រយោគអាចធ្វើសម្រង់ឱ្យជាប់បន្ថែម ក្រោយពីមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡាតាមភាពជាក់ស្តែង និងតាមសំណើររបស់គណៈមេប្រយោគ។ បេក្ខជនស្វ័យរិនមិនធ្វើសម្រង់ឱ្យជាប់បន្ថែមឡើយ។

**ប្រការ ៣៩-** គណៈមេប្រយោគមណ្ឌលប្រឡងនីមួយៗ ត្រូវប្រជុំពិភាក្សារួមដើម្បីសម្រេចលទ្ធផល នៃការប្រឡង។ កំណត់ហេតុ និងបញ្ជីចាំបាច់នានាភ្ជាប់មកជាមួយត្រូវបញ្ជូនទៅក្រសួងអប់រំ យុវជន

និងកីឡា (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ) ជាពីរច្បាប់ដើម្បីសុំសេចក្តីយល់ព្រម។

**ប្រការ ៤០-** និទ្ទេសត្រូវបានកំណត់តាមពិន្ទុប្រឡងដូចតទៅ ÷

* ចំពោះបេក្ខជននៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជន :

| | | |
|---|---|---|
| ចាប់ពីពិន្ទុ ២៥០ | ទៅពិន្ទុ ៣២៤ | និទ្ទេស : មធ្យម |
| ចាប់ពីពិន្ទុ ៣២៥ | ទៅពិន្ទុ ៣៩៩ | និទ្ទេស : ល្អបង្គួរ |
| ចាប់ពីពិន្ទុ ៤០០ | ឡើងទៅ | និទ្ទេស : ល្អ |

* ចំពោះបេក្ខជនស្វ័យរិន :

| | | |
|---|---|---|
| ចាប់ពីពិន្ទុ ២០០ | ទៅពិន្ទុ ២៥៩ | និទ្ទេស : មធ្យម |
| ចាប់ពីពិន្ទុ ២៦០ | ទៅពិន្ទុ ៣១៩ | និទ្ទេស : ល្អបង្គួរ |
| ចាប់ពីពិន្ទុ ៣២០ | ឡើងទៅ | និទ្ទេស : ល្អ |

**ប្រការ ៤១-** បទបញ្ញត្តិ ស្តីពីការរៀបចំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ពីមុនៗទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករ។

**ប្រការ ៤២-** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តតាមភារកិច្ចរៀងៗខ្លួន ដើម្បីឱ្យបានសម្រេចនូវប្រកាសនេះ។

ភ្នំពេញ ថ្ងៃទី ... ឆ្នាំ ២០០៦

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**បណ្ឌិត គឹម សេង**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
  «ដើម្បីសូមជ្រាបជាពត៌មាន»
- សាលាខេត្ត-ក្រុង
- គ្រប់អង្គភាពនៃក្រសួងអប់រំ យុវជន និងកីឡា
  «ដើម្បីជ្រាបជាពត៌មាន និង ជួយសហការ»
- មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង
  «ដើម្បីអនុវត្ត»
- កាលប្បវត្តិ
- ឯកសារ-នា.មបទ.